# ជំងឺដុំខ្មៅក្នុងសាច់ត្រី

## ១-មូលហេតុបង្កជំងឺ

មេរោគបង្កជំងឺ គឺ ព្រូននីអូដីផ្លូសស្តូមមូមអូទីកូលា & Neaseuseuticola & Tetracotyle euticola ។ វាស្ថិតនៅក្នុងអំបូរជាមួយគ្នាជាមួយព្រូន Diplostomum ។ Neodiplostomum មានប្រវែង 0,៥ - ២មម ចែកចេញជាពីរផ្នែកគឺ

. ផ្នែកក្បាល មានរង្វង់មាត់សំរាប់ជញ្ជក់ រហូតដល់បំពង់អាហារ

. ផ្នែកខ្លួន មានពោះវៀនដែលបែកជាខ្នែងពីរ និងមានរង្វង់ពោះសំរាប់តោង ។

- ខួបជីវិតរបស់ព្រូន Neodiplostomum

ព្រូនពេញវ័យរស់នៅក្នុងពោះវៀនសត្វស្លាប សត្វស្លាបស៊ីត្រី ។ បន្ទាប់មកវាទំលាក់ពងតាមអាចម៍របស់សត្វស្លាបទៅក្នុងទឹក ។ ពងព្រូនញាស់ក្នុងទឹកក្លាយជាកូនញាស់ Meracidium រាងមូលពងក្រពើមានរោមជាច្រើន Meracidium ហែលសេរីក្នុងទឹករួចទន្ទ្រានចូលក្នុងខ្យង Limnaeastagnalis ពេលនោះវាបាតអស់រោម និងរីកលូតលាស់ក្លាយជា Sporoeyta បន្ទាប់មកក្លាយជា Redia ចូលទៅក្នុងថ្លើមខ្យងក្លាយជា Cercaria ។ Cercaria ចេញពីខ្យងហែលសេរីក្នុងទឹកជួបនិងត្រីវាទន្ទ្រានចូលក្នុងសាច់ត្រីតាមស្បែក និងស្រកី ។ Cercaria រស់នៅក្នុងសាច់ដុំត្រីក្លាយទៅជា Metacercaria ដែលមានភ្នាសពន្ធ័ជុំវិញ ។ សត្វស្លាបស៊ីត្រីដែលមានកូនព្រូន Metacercaria ចូលទៅក្នុងប្រពន្ធ័រំលាយអាហារពេលនោះក្រពេញរំលាយអាហារ សត្វស្លាបធ្វើអោយរំលាយភ្នាសពន្ធ័ជុំវិញ កូនព្រូនវាលូតលាស់ក្លាយជាព្រូនពេញរូបរាង នៅក្នុងពោះវៀនសត្វស្លាប ហើយបន្តខួបជីវិតដូចដើមឡើងវិញ ។




## ២-លក្ខណៈនៃជំងឺ

កូនព្រូន Neodiplostomum រស់នៅក្នុងសាច់ដុំត្រីរស់ ត្រីអណ្តែង ដោយមានភ្នាស់យ៉ាងក្រាស់ពណ៌ខ្មៅពទ្ធ័ជុំវិញ ។ ពេលត្រីមានជំងឺនេះគេហៅថា ជម្ងឺដុំខ្មៅសាច់ត្រី មិកសាច់ត្រី ។ ត្រីឈឺធ្វើសកម្មភាពតិច ហែលយឺតលើផ្ទៃទឹក ដែលងាយស្រួលធ្វើជាចំណីដល់សត្វស្លាប ។ ត្រីមានជំងឺលូតលាស់យឺត ស្គមជួនកាលមានទំរង់រូបរាងមិនប្រក្រតី ។

## ៣-វិធីបង្ការោគ

នៅក្នុងបឹង អាងទឹកធម្មជាតិមានការលំបាកខ្លាំងនៅក្នុងស្រះចិញ្ចឹមត្រី ត្រូវបំបាត់ចោលពពួកខ្យង និងដេញបាញ់សត្វស្លាបដែលជាភ្នាក់ងារចំលងជំងឺ ។

# កត្តាមួយចំនួនដែលបណ្តាលអោយត្រីឈឺ

ទឹកជាមជ្ឈដ្ឋានរស់នៅរបស់ត្រី។ ត្រីរស់នៅធំធាត់បានដោយសារមជ្ឈដ្ឋានរស់នៅល្អពេលដែលមជ្ឈដ្ឋានរស់នៅមានការប្រែប្រួល ប្រភេទត្រីណាដែលមិនសំរបសំរួលជាមួយមជ្ឈដ្ឋានដែលប្រែប្រួលនោះ ងាយនឹងរងនូវជំងឺ ។

ត្រីដែលឈឺទទួលនូវឥទ្ធិពលអំពីកត្តាពីរយ៉ាងគឺ កត្តាខាងក្នុង និងកត្តាខាងក្រៅខ្លួនត្រី ។

## I - **កត្តាខាងក្រៅ**

### ១-កត្តាធម្មជាតិ

**ក-សីតុណ្ហភាពទឹក** ពេលសីតុណ្ហភាពទឹកប្រែប្រួលរហ័ស និងប្រថុចប្រថែពេកបណ្តាលអោយត្រីឈឺ។ ចំពោះកូនត្រីម្សៅក្នុងអាងភ្ញាស់ ការប្រែប្រួលសីតុណ្ហភាពមិនត្រូវលើសពី ២ អង្សាសេ ។ ពេលផ្ទេរកូនត្រីពូជពីស្រះមួយទៅស្រះមួយសីតុណ្ហភាពទឹកមិនត្រូវខុសគ្នាលើសពី ៤ អង្សាសេឡើយ ។ សីតុណ្ហភាពទឹកប្រែប្រួលធំពេកអាចបណ្តាលឱ្យកូនត្រីស្លាប់ទាំងហ្វូង ។

**ខ-កំរិត $P^H$** $P^H$សមស្របសំរាប់ត្រីចិញ្ចឹមក្នុងស្រះពី ៧-៨,៥ ពេល $P^H$ តូចជាង ៥ ឬ ធំជាង ៩,៥ និងបណ្តាលអោយត្រីស្លាប់ ។

**គ-$O_2$ រលាយក្នុងទឹក** បរិមាណ $O_2$ រលាយក្នុងទឹកសមស្របសំរាប់ត្រីចិញ្ចឹមពី ៣-៥ Mg /L ទឹកពេល$O_2$ រលាយក្នុងទឹកមាន 1 Mg /L ទឹក ត្រីនឹងបើបក្បាលមកស្រូបយក $O_2$ ពីក្នុងបរិយាកាសហើយ ក្នុងរយះពេលខ្លីប្រសិនបើកំរិត$O_2$ រលាយក្នុងទឹកមិនកើនឡើងទេនោះត្រីស្ទះដង្ហើមងាប់ ។

**ឃ-សមាសភាពគីមី និងសារធាតុពុលក្នុងទឹក** នៅក្នុងស្រះចិញ្ចឹមត្រីខ្លះ មានសារធាតុសំណ សង្កសី បារ៉ត និងដែកមានក្នុងដីជាមួយបរិមាណដ៏ច្រើនបណ្តាលអោយត្រីមានជំងឺ ។ ការរីកចំរើននៃឧស្សាហកម្មប្រភពទឹកដែលទទួលឥទ្ធិពលនៃការបង្ហូរកាកសំណល់នៃរោងចក្រធ្វើអោយទឹកមានជាតិពុលបណ្តាលអោយត្រីឈឺ

### ២-កត្តាមនុស្ស

**ក- ដង់ស៊ីតេដាក់ត្រីចិញ្ចឹម** ដង់ស៊ីតេត្រីចិញ្ចឹមក្នុងស្រះពី ៣-៥ ក្បាល/ម$^2$ ផ្ទៃទឹក។ ប្រសិនបើដង់ស៊ីតេដាក់ត្រីខ្ពស់ពេកបណ្តាលអោយត្រីខ្វះ $O_2$ និងខ្វះចំណីដែលអាចបណ្តាលអោយត្រីឈឺ ។

**ខ- ការគ្រប់គ្រងស្រះចិញ្ចឹមត្រី** ការគ្រប់គ្រង និងអោយចំណីតាមបច្ចេកទេសចិញ្ចឹមធ្វើអោយត្រីមានសុខភាពល្អ មានការលូតលាស់ធំធាត់បានល្អ ផ្ទុយទៅវិញប្រសិនបើការចិញ្ចឹមពុំបានត្រឹមត្រូវតាមបច្ចេកទេសដូចជាអោយចំណីអាហារគ្មានអនាម័យ មិនធ្វើអនាម័យស្រះជាដើម បណ្តាលអោយស្រះកខ្វក់មានមេរោគធ្វើអោយត្រីឈឺ ។

**គ-ធ្វើអោយត្រីមានរបួស** ពេលកៀរអួន ឬសំណាញ់ចាប់ត្រីធ្វើអោយត្រីមានរបួសរលាត់ ក្នុងពេលដឹកជញ្ជូន ឬ ផ្ទេរទៅស្រះផ្សេងបណ្តាលអោយត្រីងាយរងនូវការជ្រៀតចូលរបស់មីក្រុប។

**៣-កត្តាសត្វ** ជម្ងឺត្រីភាគច្រើនបណ្តាលមកពីពពួកមីក្រុប ប៉ារ៉ាស៊ីតជាដើមបង្កជាជម្ងឺដល់ត្រី ។ ក្រៅពីនោះមានពពួកសត្វដែលស៊ីត្រី និងពពួកសត្វដែលធ្វើអោយត្រីមានគ្រោះថ្នាក់ ឬ សត្វស្លាបទឹក ពស់ត្រី សត្វល្អិតក្នុងទឹក។ល។